# សុភាសិតខ្មែរ

## តាមលំដាប់អក្សរ

ឃុន និពន្ធមន្ត្រី ញ៉ុក ថែម អ្នកតែង

រៀបរៀងដោយ

ខ្ញុំបាទ ហៀន វិចិត្រ

ព.ស.២៥៦៣

# សុភាសិតខ្មែរ

## តាមលំដាប់អក្សរ

**ឃុន និពន្ធមន្ត្រី ញ៉ុក ថែម អ្នកតែង**

រៀបរៀងដោយ

ខ្ញុំបាទ ហៀន វិចិត្រ

**ព.ស.២៥៦៣**

# អារម្ភកថា

យោងទៅតាមឯកសារចាស់ ខ្ញុំបានយល់ឃើញថា មិនសូវមានអ្នកបានអានទេព្រោះច្បាប់ដើមនៅច្រើនកន្លែងពេក មិនមានរយៈនៅជាប់គ្នាឡើយ ។ ខ្ញុំក៏សម្រេចចិត្តប្រមូលវា ដាក់តែមួយច្បាប់ ដើម្បីស្រួលអាន ក្នុងការសិក្សាស្រាវជ្រាវ ។ **សុភាសិតខ្មែរ** គឺជាវាចា ពីរោះរបស់អ្នកប្រាជ្ញជាន់មុន ថែមទាំងការស្រឡាញ់ក្នុងអក្សរសាស្ត្រផងនោះ ខ្ញុំក៏ចំណាយពេលចងក្រងតាមច្បាប់ដើមទុកជាទីនឹករលឹកដល់អ្នកប្រាជ្ញខ្មែរ ក្នុងសៀវភៅនេះបើមានអក្ខរាវិរុទ្ធណាខុសក៏សូមខន្តីអភ័យទោសផង សូមផ្តល់ជាមតិយោបល់ដល់ខ្ញុំផង ។

យោងតាមការខំប្រឹងប្រែងរបស់ខ្ញុំកន្លងមក ខ្ញុំសូមប្រមូលបុណ្យកុសលទាំងអស់ដែលខ្ញុំមាន សូមឧទ្ទិសជូនដល់បុព្វបុរសខ្មែរ ព្រមទាំងញាតិខ្ញុំទាំងអស់ សូមបាននូវសេចក្តីសុខរួចចាកទុក្ខទាំងឡូង និងមិត្តអ្នកអានសៀវភៅសូមបានបុណ្យស្មើខ្ញុំដែរ សូមអនុមោទនា!!! ។

ថ្ងៃព្រហ. ទី២២ ខែសីហា ឆ្នាំ២០១៩

ដោយ ហៀន វិចិត្រ



# ក

១ .កទន្សេងខ្នងជាងបេក ជើងកន្ទេកភ្នែកល្អក់ ។

២ .កក់ក្តៅដូចគេអាំងផែះ ។

៣ .កប់ពពកជ្រកអាចម៍ជន្ទេន ។

៤ .កាន់កពស់ឲ្យខ្ជាប់ ក្រែងក្រឡាប់ខាំឯប្រាណ ។

៥ .កាប់បំពង់រង់ទឹកភ្លៀង ។

៦ .ការក្រកុំគិតឆ្ងាយ ការសម្ពាយជាកម្រោល ។

៧ .ការពារទុក ស្រណុកជាងកែខៃ ។

៨ .កាលខ្លីកុំធ្វើវែង កាលវែងកុំកាត់ឲ្យខ្លី ។

៩ .កាលដែលឈឺធ្ងន់យកដំរីទៅបន់ ដល់ជម្ងឺស្រន់ យកពងមាន់ ១ ទៅថ្វាយ ។

១០ .កាលពីក្មេងឲ្យស្វែងរៀនចំណេះ ដល់ធំឲ្យចេះរកសម្បត្តិ ដល់ទៅចាស់ឲ្យស្វះកាន់សីលសត្យ ហៀបនឹងស្លាប់ឲ្យហាត់ចិត្តភាវនា។

១១ .កុកច្រើនភ្លេចតែជង់ តែឯជង់មិនភ្លេចកុក ។

១២ .កុកហើរលើមេឃលែងអ្វីជាប់ជង់ ( ស្រអែមមានទ្រង់លែងអ្វីជាប់ជង់បង ) ។

១៣ .កូនក្រោលបង្គោលស្នឹង ។

១៤ .កូនគេក្រមុំ កុំយកខ្លួនផ្តេកផ្តិតឡើយណា ។

១៥ .កូនជាស្មៅ ចៅជាអង្កាម ។

១៦ .កូនមួយតៅ ចៅមួយថាំង ។

១៧ .កូនឥតមេថា ឥតបាប្រដៅ ។

១៨ .កូនអើយរកស៊ី កកាយធរណី នោះឯងប្រពៃ ។

១៩ .កើតជាប្រពើមិនលែងអកក្រួស ធ្វើជាចៅក្រមមិនលែងនិយាយហួស ធ្វើជាអ្នកបួសមិនលែងត្រូវអាបត្តិ ។

២០ .កើតជាជន្ទេនមិនខ្ចើមដី កើតជាមន្ត្រីមិនខ្ចើមប្រាក់ ធ្វើជាជាងធ្វាក់មិនខ្ចើមឈើ ។

២១ .កើតជាអ្នកចំបាំងកុំរាសឹក កើតជាអ្នកប្រមឹកកុំរាពែង ។

២២ .កោកៗ សឹកតែមាត់ត្រដោក ឆ្អែកឯពោះក្របីគាង ។

២៣ .កុំកោកៗ អាងឋាន ព្រៃស្មសានឋានកំបាំង ។

២៤ .កុំក្តិចសង្ហាប្រជល់គ្នា ។

២៥ .កុំខ្ទើកតាមខ្យល់ កុំខ្វល់តាមរលក ។

២៦ .កុំគិតប្រូតស្បូវបាំងវាល ។

២៧ .កុំគិតត្រង់សំដីគេនិយាយ ត្រូវគិតត្រង់អំពើដែលគេធ្វើ ។

២៨ .កុំជឿងដោយខ្យល់ កុំឱនពាក្យពល កុំខ្វល់ដោយស្រី ។

២៩ .កុំចាប់ត្រីដៃពីរ ។

៣០ .កុំយកអំពៅទៅផ្ញើនឹងដំរី ។

៣១ .កុំស៊ីត្រង់ណា ជុះត្រង់នោះ ។

៣២ .កុំជឿមេឃ កុំជឿផ្កាយ កុំជឿកូនថាគ្មានសហាយ កុំជឿម្តាយថាគ្មានបំណុល ។

៣៣ .កុំឈ្លោះនឹងស្រី កុំជួញនឹងមន្ត្រី កុំក្តីនឹងចិន ។

៣៤ .កុំត្រាប់គំនិតឆ្កែតឿ កុំត្រាប់ពុកជ្រៃ ។

៣៥ .កុំត្រាប់ពុតមេអំបៅ ជៀលដង្កូលថាថោកទាប ។

៣៦ .កុំត្រាប់ពុតត្រីឆ្តោរ ជាមច្ចោស៊ីកូនឯង ។

៣៧ .កុំទុកក្នុងស្នុគ្គស្នូញនៅ ក្រែងដល់យូរទៅខាតខូចអសារ ។

៣៨ .កុំទុកចិត្តបរទេស កុំទុកចិត្តអភិនេស្កម៍ កុំទុកចិត្តអភិប្រាយ ។

៣៩ .កុំទុកចិត្តស្រី កុំប្រណីចិត្តសត្វ ។

៤០ .កុំទប់ទឹកហូរពីលើភ្នំ ។

៤១ .កុំទុំមុនស្រគាល ។

៤២ .កុំបីយកសំរឹទ្ធិ ផ្ញើនឹងអ្នកស្និតនោះពុំជា ។

៤៣ .កុំបោះសន្ទូចរំលងភ្នំ (កុំរំលំឈើស៊ីផ្លែ) ។

៤៤ .កុំពត់ស្រឡៅ កុំប្រដៅស្រីខូច ។

៤៥ .កុំពូតផ្សែងជាដុំ ផ្ទុំឆេះជាភ្លើង ។

៤៦ .កុំយកកទៅលអន្ទាក់ ។

៤៧ .កុំយកថ្មុកធ្វើជាថ្នល់ ។

៤៨ .កុំយកផ្ទះធ្វើជាក្តី កុំយកស្រីធ្វើជាគ្រូ ។

៤៩ .កុំយកមេឃទ្រាប់អង្គុយ ។

៥០ .កុំយកពងមាន់ទៅផ្ញើនឹងក្អែក ។

៥១ .កុំយកផ្ទិនជាធៅ កិច្ចក្នុងក្រៅមានតម្រា ។

៥២ .កុំយកស្ករទៅផ្ញើនឹងស្រមោច ។

៥៣ .កុំស្អប់ម៉ែឪ កុំសត្រូវនឹងវៀមច្បង ។

៥៤ .កុំរេងមុខដឹង កុំទទឹងមុខសឹក ។

៥៥ .កុំលត់ភ្លើងពីក្រោមខ្យល់ ។

៥៦ .កុំស៊ីបាយនឹងមនុស្សឆ្កួត កុំកាច់ឧសប្រកួតនឹងដំរី ។

៥៧ .កុំស្និទ្ធនឹងសត្វមានស្នែង កុំប្រលែងនឹងសត្វមានចង្កូម ។

៥៨ .កុំអរនឹងយស កុំជាទុក្ខដ្បិតថ្វស់ ។

៥៩ .កុំអាងមានទ្រព្យច្រើន ពុំក្រវើនរកផ្គង់ផ្គត់ ។

៦០ .កុំអាងអួតអាត្មា បេះតម្រាពីព្រេងនាយ ។

៦១ .កុំអួតខ្លួនខ្លាំង រត់ប្រណាំងនឹងស្រមោល ។

៦២ .កុំឲ្យស្ត្រីញាប់វាធ្លាប់ផ្ទួន កុំឲ្យថ្នមខ្លួនវាធ្លាប់ខ្ជិល ។

៦៣ .កុំឲ្យចង្វាចឹក សូវចុះទឹកឲ្យក្រពើខាំ ។

៦៤ .កំជិលអៀនប្រៀន បួសហើយមិនរៀន បន្ទោសថាខ្ចៅ ។

៦៥ .កំប្រុកស៊ីផ្លែល្វា ជំពាក់កទា ទៅផ្សាឯក្តិតឈ្លូស ។

៦៦ .កំពង់មិនដែលស្ងាត់ រីឯមាត់មិនដែលស្ងៀម ។

៦៧ .កំភ្លាញស្លាប់ពីព្រោះមាត់ ខ្វែកស្លាប់ពីព្រោះអាចម៍ ។

៦៨ .កំលោះក្រមុំជុំសុទ្ធតែផ្កា មានប្តីកាលណា ក្លិនដូចរោមភេ ។

៦៧ .កំឡាំងនៅស្រមោច ឫទ្ធិនៅខ្មោច អំណាចនៅក្មេង ។

៦៨ .កាំត្រាច កាំធ្នង់ (កង់ត្រាចកង់ធ្នង់) ។

៦៩ .កាំបិតចិតដងឯង ។

៧០ .កាំបិតឯង វាកាប់កឯង ។

៧១ .ក្ដាមនៅស្រែណា វាកាត់ស្រូវស្រែនោះ ។

៧២ .ក្ដីក្រកុំគិតងាយ ការសម្ងាយជាកំរោល សន្សឹមកុំបំបោល
ក្រែងពុំដល់ដូចប្រាថ្នា ។

៧៣ .ក្ដីក្រកុំគិតស្រាយ ក្ដីងាយកុំធ្វេស ។

៧៤ .ក្ដៅរកវែក ត្រជាក់លូកនឹងដៃ ។

៧៥ .ក្ដៅស៊ីរាក់ ត្រជាក់ស៊ីជ្រៅ ។

៧៦ .ក្អែកមួយជាក្អែក១០ ។

៧៧ .ក្រកិច្ចក្រកល ក្រដឹងក្រយល់ ក្រវៃឆ្នៃទាស់ ។

៧៨ .ក្រធ្ងន់គំនិត ក្រគិតគុណគេ ក្របានជាមេ បាគេទាំងឡាយ។

៧៩ .ក្របីស្នែងកែក មនុស្សស្រលៀងភ្នែក ក្រពើកំបុតកន្ទុយ ។

៨០ .ក្រមានពាក្យសត្វ ក្រចិត្តអាចកាត់ ស្រឡះពីស្នេហ៍ ។

៨១ .ក្រអ៊ីចំណោះ ក្រតែស្នេងតិះ នឹងនប់ទីទុយ ។

៨២ .ក្រអ៊ីប្រពន្ធ ក្រតែទ្រព្យធន នឹងប្រដាប់ខាន់ស្លា ។

៨៣ .ក្រួចមិនជូរ ជូរជួសក្រូច ។

៨៤ .ក្រៀលដៀលក្រួច ក្រួចមាត់ក្រហួច វាដៀលក្រៀលវិញដែរ ។

## ខ

១ .ខឹងគេ វាយកូនឯង ។

២ .ខឹងឲ្យអត់ ខ្សត់ឲ្យរក ឲ្យច្រើនកុំយក ខ្លាចឲ្យចូលជិត ។

៣ .ខំរៀនទើបបានចេះដឹង ខំប្រឹងទើបបានកើត ។

៤ .ខ្ពស់ហើយខំប្រឹងចង្អើតទៅទៀត ។

៥ .ខ្ពើមលាមកជិះដំរី ខ្ពើមដីឡើងចុងឈើ ។

៦ .ខ្មាសគ្រូគ្មានប្រាជ្ញា ខ្មាសភរិយាគ្មានកូន ។

៧ .ខ្មាសមិនឈ្នះឃ្លាន មានមិនឈ្នះមិត្រ ។

៨ .ខ្លាក្រាបកុំថាខ្លាសំពះ ។

៩ .ខ្លាទាល់ច្រក រលកទាល់ច្រាំង ( រលកទាល់ច្រាំង រមាំងទាល់ច្រក ) ។

១០ .ខ្លាំពឹងព្រៃស្តុក ក្របីពឹងភក់ សង្ឃកំពង់សត្វ ក្សត្រជាឆត្ររាស្ត្រ ។

១១ .ខ្លាមិនខ្លាចទៅខ្លាចឯអាចម៍ខ្លា ។

១២ .ខ្លារំពឹងព្រៃ ព្រៃរំពឹងខ្លា ។

១៣ .ខ្លួនជាអាចារ្យ ចិត្តជាអាចោរ ។

១៤ .ខ្លួនទាបកុំតោង ដៃខ្លីកុំឈោង ប្រវាឱបភ្នំ ។

១៥ .ខ្លួនធំខំរកស៊ី ចាស់ព្រឹទ្ធិគួរអនិច្ចា ។

១៦ .ខ្លួនរស់របស់បាន ខ្លួនស្លាប់របស់លាញ ។

១៧ .ខ្វែងហើរដ្បិតខ្យល់ នាយថ្កើងដ្បិតពល រក្សាឲ្យសុខ ទ្រព្យគង់ដ្បិតស្រីចេះសំចៃទុក ផ្ទះធំស្រណុក ដ្បិតភរិយាជា ។

១៨ .ខ្មៅវែងស្អប់ចេះ ខ្សត់ឥតចំណេះ ស្អប់អ្នកមានទ្រព្យ ។

១៩ .ខ្វាក់បានដៃ អាអូតបានគុម្ពឫស្សី ។

២០ .ខ្វាក់បានដៃ ខ្វិនខ្វៃបានជើង ។

# គ

១ .គយដេកដាស់គយឲ្យអង្គុរ ។

២ .គាប់នឹងស្រា ជានឹងបាយ ។

៣ .គិតច្រើនវាឃ្លាត ដេកច្រើនវាកើតព្យាធិ ។

៤ .គិតរួចសឹមគូរ ។

៥ .គុណមិនឈ្នះគាប់ ទ្រព្យមិនឈ្នះត្រូវ ។

៦ .គូររូបខ្លាឲ្យគោខ្លាច ឬគូររូបខ្លាបង្អើលគោ ។

៧ .គេខុសកុំអាលអរ គេសាទរកុំអាលអួត ។

៨ .គេប្រាប់កុំអាលឆោត គេបំពោតកុំអាលភ្ញាក់ ។

៩ .គេប្រើកុំអាលទៅ គេហៅកុំអាលមក គេឲ្យកុំអាលយក គេសង្ស័យកកុំអាលថយ ។

១០ .គេស៊ីពង ឯងរងសំបុក (កាលណាកើតឧកឡុក វារយោងដូចសម្កកំពឹស ។

១១ .គេស្លាប់កុំអាលយំ យល់គេធំកុំអាលត្រេក ។

១២ .គេឲ្យដើរមុខមិនចេះបង់បោយ គេឲ្យដើរក្រោយមិនចេះវៃក ។

១៣ .គោគេមិនអួត អួតតែគោឯង ។

១៤ .គោដំបៅខ្នង ក្អែកហើររំលងរំភាយកន្ទុយ ។

១៥ .គោផ្អើលមិនគិត ទៅគិតឯទាស់គ្នា ។

១៦ .គោមួយក៏យប់ គោដប់ក៏ល្ងាច ។

១៧ .គោលឿនសឹកក ស្រីល្អសឹកគូថ ។

១៨ .គោសាំងខ្វាំងជល់ ។

១៩ .គោស្គមថ្មមប្រើ ។

២០ .គំនិតលើខ្លួន ទៅពួនស៊ីឯស្ទឹកថ្មីង ។

២១ .គំនុំព្នង បំណងស្ដេច ។

## ឃ

១ .ឃើញខ្លាធ្លាក់អណ្ដូងហើយ ម្ដេចឡើយយកដុំថ្មទៅបន្ទក់លើគ្នា ទៀត ។

២ .ឃើញឈើពុក កុំអាលដាក់គូថអង្គុយ ។

៣ .ឃើញដំរីជុះ កុំជុះតាមដំរី ។

៤ .ឃើញសេះថាជាលា ឃើញគជាថាកណ្ដុរ ។

៥ .ឃើញទុងហើរ កុំសរសើរថាទុងរបស់ឯង ។

៦ .ឃើញមនុស្សដួល កុំដើរកន្ទួង ។

៧ .ឃ្លានកុំអាលស៊ី ។

៨ .ឃ្លោកលិចអម្បែងអណ្ដែត (ឃ្លោកលិច ថ្មអណ្ដែត) ។

៩ .ឃ្វាលក្របីជិះក្របី ។

## ង

១ .ងប់នឹងល្បែងតែងហិនហោច ។

២ .ងាយមិនក្រៃណានឹងបាន មានប៉ុន្មានមិនក្រៃនឹងអ្នកដំបានសុខ ចេះក្តីមិនក្រៃណានឹងអ្នកម្ចាស់ស្រុក ។

៣ .ងើយវាស្អក ឱនវាដាក់គ្រាប់ ។

៤ .ងាប់ដូចពស់ រស់ដូចកង្កែប ។

## ច

១ .ចង់គាប់ប្រើស្វះស្វែង រករៀនវិះសរពើក្តី ។

២ .ចង់ចេះឲ្យសម្លាប់អាចារ្យ ចង់បានផ្លែផ្កាឲ្យយកភ្លើងដុតគល់ ចង់បានកុសលឲ្យបង្អត់បាយ ។

៣ .ចង់ចេះឲ្យធ្វើល្ងង់ ។

៤ .ចង់ឆ្ងាញ់ឲ្យរកអន្ទក់ ចង់ស្រណុកឲ្យនឿយពីក្មេង ។

៥ .ចង់បុណ្យបានបាប ចចើងចង់លាភវែងបាត់ធនទៅ ។

៦ .ចង្អៀតចិត្តនៅមិនបាន ចង្អៀតផ្ទះនៅបាន ។

៧ .ចាក់អង្ករយកអង្កាម ។

៨ .ចាញ់ចត្រង្គអស់ប្រាជ្ញា ចាញ់តណ្ហាអស់កុសល ចាញ់យោបល់អស់នគរ ។

៩ .ចាញ់បានជាព្រះ ឈ្នះបានជាមារ ។

១០ .ចាញ់ល្បែងអស់ទ្រព្យធន ចាញ់ប្រពន្ធអស់សិរីចាញក្ដីអស់គំនិត។

១១ .ចានមួយរាវលែងអ៊ីវណ្ដំគ្នា ។

១២ .ចាប់នេះចាប់នោះមិនត្ដោះត្រង់ណា ។

១៣ .ចាប់ច្រវាសំឡឹងជ្រោយ[(១)] ។

១៤ .ចាប់វល្លិមួយ រារញ្ជួយរាល់ដើម ។

១៥ .ចាស់អាងស្ងាប់ ពាលអាងកាប់ ក្មេងអាងយំ ។

១៦ .ចិត្តចង់កុំអាលស៊ី យល់តែស្រីកុំអាលចង់ ។

១៧ .ចិត្តជាទេវទត្ត មានជាទេវតា ។

១៨ .ចិត្តដាច់នៅស្រី ។

១៩ .ចិញ្ចឹមមនុស្សឲ្យមើលចិត្ត ចិញ្ចឹមសត្វឲ្យមើលចង្កូមវា ។

២០ .ចិត្តល្អក្រខ្លួន ។

២១ .ចាស់ជាសួរបង់ទ្រព្យខូចវាហើ ខូចសំដីបង់គំនិតពិបាកស្រាយ ។

២២ .ចុះទឹកប្រទះក្រពើ ឡើងលើប្រទះខ្លា ។

២៣ .ចូលស្ទឹងតាមបត់ ចូលទូកតាមកំពង់ ចូលស្រុកតាមប្រទេស ។

២៤ .ចូលព្រៃសត្វសាហាវ រកអំពារគ្នាមកជុំដល់បានស្ករទឹកឃ្មុំ ពួនក្នុងផ្ទះស៊ីម្នាក់ឯង ។

២៥ .ចេះគេថាកាច ប្រាជ្ញគេថាព្រើល ។

២៦ .ចេះច្បាប់មិនខ្លាចក្ដី ចេះវិន័យមិនខ្លាចអាបត្តិ ។

២៧ .ចេះមកពីរៀន មានមកពីរក ។

---

(១)ហុតទឹកសំឡឹងកាក ចាបច្រវាក្រាកសំឡឹងជ្រោយ ។

២៨ .ចោលសាច់ស្រវាឆ្អឹង ទំពាទៅរឹងបែរទៅរកសាច់វិញ ។

២៩ .ចៅហ្វាយមានបុណ្យខ្ញុំមានសក្តិ ចៅហ្វាយអប្បលក្ខណ៍ខ្ញុំធ្លាក់អណ្តូង។

៣០ .ចំបាប់លោកសង្ឃ ខ្វាចអ្វីត្រង់ព្រះសិរ ។

៣១ .ចំណីច្រើនមុខច្រើនពិសា កូនច្រើនបាច្រើនតែល្អ ។

៣២ .ចំណីឆ្ងាញ់កុំទុកដល់ថ្ងៃស្អែក ប្រពន្ធគាប់ភ្នែកកុំឲ្យដើរក្រោយ ។

៣៣.ចំណោះជិះកឯង ។

៣៤ .ចាំក្បួនចាំឲ្យស្ទាត់ កុំអៀនប្រៀនផ្សំពាក្យពោល ។

៣៥ .ច្រងោប៉ុនគល់ មិនយល់ប៉ុសក់ ។

៣៦ .ច្រើនចេះរបេះក្បាច់ ។

# ឆ

១ .ឆ្កែខាំឲ្យរកម្ចាស់ គោឆ្កេះឲ្យរកនាយ ។

២ .ឆ្កែព្រុសមិនដែលខាំ ផ្គរលាន់មិនដែលភ្លៀង ។

៣ .ឆ្កែទាល់ច្រក រលកទាល់ច្រាំង ។

៤ .ឆ្មាមិននៅ កណ្តុរឡើងរាជ្យ ។

៥ .ឆ្អឹងស្រែក ស្បែកហៅ ។

# ជ

១ .ជាងទងស៊ីរងកំបែក ជាងដែកហែកនឹងដៃ ។

២ .ជាងមិនកើត បន្ទោសដែក ។

៣ .ជួញជិតជាជាងជួញឆ្ងាយ ជួញក្បែរវៀងអាយរក្សាប្អូនស្រី ។

៤ .ដើងក្រោយដោយតាមដើងមុខ ។

៥ .ដើងទេញធ្មេញល្អិត ស្លឹកត្រចៀកកំប៉ិត គំនិតរបិញរបុញ ។

៦ .ដើងបួនគង់មានភ្លាត់ ប្រាជ្ញបេះស្មាត់គង់មានភ្លាំង ។

៧ .ដើងបួនគង់មានជ្រុល អ្នកបេះពេញផ្លុលគង់មានជ្រួស ។

៨ .ជំពប់ដើងគង់បាក់ ជំពប់មាត់បង់ប្រាក់ ។

៩ .ជ្រៃលោមស្រឡៅ ត្រាវលោមបឹង ។

# ឈ

១ .ឈើដើងជាត់ ឈើមាត់ស្គម ។

២ .ឈើកោងវល្លិព័ទ្ធ មនុស្សខ្វាត់ភ្វាត់កុំឲ្យយកខ្លួនបៀត ។

៣ .ឈើធំរលំព្យុខ្លាំង ។

៤ .ឈើផ្លែចាញ់សន្ទឹក ត្រីច្រើនទឹកល្អក់ពុំជា ទ្រព្យច្រើនព្រួយរក្សា ទ្រព្យតិចណាព្រួយរិះគិត ។

៥ .ឈើស្លាប់ពីចុង ដំរីងាប់ពីពុង មនុស្សស្លាប់ពីដើង ។

៦ .ឈ្នួញទឹកពិតពឹងទូក រឺឈ្នួញគោកពឹងរទេះ សំណាងពឹងចំណេះ

ប្រាជ្ញប្រាយចេះពឹងគម្ពីរ ។ ព្រះសង្ឃពឹងវិន័យ សត្វកពត្រៃពឹង ធរណី សេនាពឹងឫទ្ធិ ឯអ្នកជីពិតពឹងវត្ត។ រីមូលពឹងក្រឡឹង រីឯត្រង់ពឹងបន្ទាត់ កិរិយាពឹងសំពត់ ឯបរិសុទ្ធពិតពឹងសីល ។សត្វត្មាតពិតពឹងរុយ សាច់សត្វស្អុយពឹងអំបិល មង្គលការពឹងពពិល រក្សាសីលពិតពឹងទាន ។

## ដ

១ .ដល់កំពង់លង់ទូក ។

២ .ដង្កូវចេញពីសាច់ ច្រេះចេញពីដែក ។

៣ .ដប់នាក់អន្សមខ្លោច គ្នាដូចស្រមោចអន្សមឆៅ ។

៤ .ដាក់ទ្រូឲ្យស្រះបន្ទា អារសាច់ជូនខ្លាទើបនៅស្រុកបាន ។

៥ .ដឹកគោញី បន់ស៊ីគោឈ្មោល ។

៦ .ដឹងបានដឹងបង់ ដឹងបាត់ដឹងគង់ ដឹងគួរដឹងគាប់ ដឹងខ្ពស់ដឹងទាប។

៧ .ដឹងដប់ផ្ទប់ឈើមួយ ។

៨ .ដឹងតាមសាប់ ច្បាប់តាមពាក្យ ។

៩ .ដឹងគ្នានៅគ្រាក្រ សំបុរល្អនៅខែកត្តិក ។

១០ .ដឹងឆ្ងើយពីព្រោះដង ក្ងូនឆ្កងពីរព្រោះមេបា ។

១១ .ដឹងរង្គោះបោះបណ្ដោយ ។

១២ .ដុតឲ្យខ្លោច រោចឲ្យឆៅ ឬ ដុតទៅវាខ្លោចរោចទៅវាឆៅ ។

១៣ .ដូចក្រពើរង្វើងបឹង ។

១៤ .ដូចខ្លាក់បានដៃ ។

១៥ .ដូចគេចិញ្ចឹមកូនខ្លា ។

១៦ .ដូចចាប់ក្តាមដាក់ចង្អេរ ។

១៧ .ដូចចាប់ស្វាមកបំបួស ។

១៨ .ដូចចាបគេយកអន្ទង់ ទៅចំហុងនឹងកក់

១៩ .ដូចជាគេអូសឫស្សីពីចុង ។

២០ .ដូចជាគេអូសក្ដែឲ្យចុះទឹក ។

២១ .ដូចជាគេប្រដៅក្រពើឲ្យហែលទឹក ។

២២ .ដូចជាទឹកកន្ទះក្អម ។

២៣ .ដូចសង្ឃឹមផ្កាយលើមេឃ ។

២៤ .ដូចអាចម៍ចូលឈ្នាង ។

២៥ .ដូចឆ្មាចូលត្រឡោក ។

២៦ .ដូចត្រឡាចនៅក្នុងបន្ទា ។

២៧ .ដូចប្រដៅសេកចាស់ ។

២៨ .ដើរឲ្យមានបី ស្រដីឲ្យមានបួន ។

២៩ .ដើរឲ្យរំពៃ អង្គុយឲ្យរំពឹង ដេកឲ្យជញ្ជឹង ខឹងឲ្យពិចារណា ។

៣០ .ដេកមិនលក់កុំខំដេក ។

៣១ .ដេកយប់កុំនិយាយនឹងស្រី ។

៣២ .ដេកយប់កុំដេកយូរ ខ្លាចក្ដីទូជំនដល់ប្រាណា ។

៣៣.ដេកលើភ្លៅ ទៅបោឯអ្នកដទៃ ។

៣៤ .ដេកផ្ទារស្តោះដាក់លើទ្រូងឯង ។

៣៥ .ដេកផ្សំដួល រមួលផ្សំគ្រេច ។

៣៦ .ដេញទាន់កុំជាន់កែង ។

៣៧ .ដៃក្ងើង ជើងមាន់ ។

៣៨ .ដំរីសារស្លាប់ទៅយកចង្អេរបាំង ។

៣៩ .ដំរីផុងព្រយុងដើមឈើ ។

៤០ .ដំរីខ្លាក់ ទ្រមាក់ឆ្កួត ។

## ត

១ .តក់ៗ ពេញបំពង់ ធុងៗ ដល់បាត ។

២ .តកំឡាំង ឲ្យសេពអាហារ ។

៣ .តដងវែកឲ្យល្មមនឹងស្នា ។

៤ .តវាសនា ឲ្យខំសន្សំបុណ្យ ។

៥ .តសំពៅមិនត្រូវស្តាយដែក ។

៦ .តឹងគិតឲ្យធូរ យូរគិតឲ្យឆាប់ ។

៧ .តឹងង៉ាង ធូរស្ងួត ។

៨ .ត្នោតបាទប្រមាទត្នោតលៃ ប្រមាត់ដីឡើងទ្រើង ។

៩ .ត្រកូលសជាតិ មារយាទសខ្លួន ។

១០ .ត្រឡប់ត្រឡិន បាយបិណ្ឌជាបាយបាត្រ ។

១១ .ត្រឡាចវារទៅ រពៅវាមក ។

១២ .ត្រង់ណាហៅច្បាប់ កាន់ខ្ជាប់កុំបីបង់ ។

១៣ .ត្រីមួយត្រក តែស្អុយមួយ ស្អុយទាំងអស់ ។

១៤ .ត្រុកៗអ្នកស្រុកមើលងាយ រលាស់កន្ទុយខ្លាយមានឱតមានភ័ន្ត ។

## ថ

១ .ថោកអីនៅដៃ ថ្លៃអីនៅមាត់ ។

## ទ

១ .ទន្លេដប់មិនស្កប់សមុទ្រមួយ ។

២ .ទឹកចូលច្រមុះ ។

៣ .ទឹកជន់ បុណ្យស្តេច ។

៤ .ទឹកថ្លាល្អិតបើល្អក់ ដ្បិតរលកខ្លាំងសោះសារ ។

១៨ .ទឹកបាក់ទៅទាប ដីខ្ពស់កណ្តៀរពូន ។

១៩ .ទឹកត្រជាក់ត្រីកុម ។

២០ .ទឹកឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី ។

២១ .ទឹកហូរមិនដែលហត់ ជាព្រះពុទ្ធមិនដែលខឹង ។

២២ .ទឹកហូរតាមប្រឡាយ ទន្សាយបោយតាមប្រឡោះ ។

២៣ .ទូកទៅ កំពង់នៅ ។

២៤ .ទូកបែកជាទូកគត់ ទូកកំបុតជាកង ។

២៥ .ទូកយើងវែង ទូកគេខ្លី ។

២៦ .ទូងៗប្រហោងក្នុង ។

២៧ .ទៅឥតគេរក មកឥតគេហៅ ។

២៨ .ទំពក់វាទៅ ទើបញ៉ៅវាជ្រុះ ។

២៩ .ទំពាំងស្នងឫស្សី ។

## ធ

១ .ធ្ងន់នៅថ្ម ក្រនៅក្តី ។

២ .ធ្ងន់អម្រែកជួយគ្នាបាន ធ្ងន់ជម្ងឺក្នុងប្រាណជួយមិនកើត ។

៣ .ធ្វើគុណបានទោស ដូចប្រោសខ្លាស្លាប់ ។

៤ .ធ្វើគុណ១០០សំពៅ ទោសមួយចូលទៅរលាយបាត់អស់ ។

៥ .ធ្វើបេះត្រូវគេប្រើ ធ្វើល្ងេល្ងើស្រណុកខ្លួន ។

៦ .ធ្វើទានធ្វើឲ្យស្មោះ កុំអាឡោះអាល័យខ្លួន ។

៧ .ធ្វើជាចៅក្រមមិនលែងនិយាយហួស ធ្វើជាអ្នកបួសមិនលែងត្រូវ
អាបត្តិ។

៨ .ធ្វើស្រែទាន់ក្តៅដី ចង់ស្រីទាន់ក្តៅចិត្ត ។

៩ .ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ ។

១០ .ធ្វើស្រែមិនបាច់ភ្ជួរ រក្សាតែមួរស៊ីស្រូវមិនអស់ ។

១១ .ធ្វើស្រែឲ្យមើលស្មៅ ទុកដាក់កូនចៅឲ្យមើលផៅសន្តាន ។

១២ .ធ្វើអ្វីធ្វើឲ្យហើយ កុំទុកឡើយបង្កើតកេរ្តិ៍ ។

# ន

១ .អ្នកមានមិនដែល ៣ត អ្នកក្រមិនដែល ៣ ជាតិ ។

២ .អ្នកដីផងដប់ មិនស្មើអ្នកប្រសប់មួយ ។

៣ .អ្នកដំកុំផ្ញើដែក អ្នកប្រមឹកកុំផ្ញើស្រា ។

៤ .អ្នកមានកុំអាលអរ អ្នកក្រកុំអាលភ័យ ។

៥ .អ្នកមានរក្សាខ្សាត់ ដូចសំពត់ព័ទ្ធពីក្រៅ ។

៦ .អ្នកមុនកំសោយ អ្នកក្រោយមានលាភ ។

៧ .អ្នកយើងកាន់គ្រោះតាមរាសី ចៅក្រមកាត់ក្តីតាមពាក្យបណ្តឹង ។

៨ .អ្នកឡើងបានតែបេះ អ្នកប្រឡេះមិនបានស៊ី ។

៩ .អ្នកហ៊ានស្បែកដាច អ្នកខ្លាចស្បែកជា ។

១០ .អ្នកដេកធាប់លក់ ដៀតតតបើគិត ។

១១ .នាងគូនឹងអ្នក មេខាតលក្ខណ៍គូនឹងអាកំបាក់ទន្សា ក្សត្រីគូនឹង ក្សត្រា ស្រីទេពកញ្ញា គូនឹងមហាក្សត្រ ។

១២ .នាងតីស្នាគាង ស៊ីរះសងខាងមិនឲ្យអន់ចិត្ត ។

១៣ .និយាយក្តីឲ្យមើលមាត្រា និយាយការឲ្យមើលទំនង ។

១៤ .និយាយច្រើនគេពុំស្តាប់ អប្បប្រាជ្ញា ។

១៥ .និយាយយប់ផ្ទប់ព្រៃ និយាយថ្ងៃព្រៃមានត្រចៀក ។

១៦ .និរាសកុំម្នេញ ខឹងកុំទន្ទេញ ស្អប់កុំព្យាបាទ ។

១៧ .និរាសគម្តែង ទុក្ខគម្តែង ខែងកុំទន្ទែង មិតកុំបណ្តោញ ។

១៨ .នឹងលេបវាស្ទាក់ នឹងខ្ជាក់វាស្ទែង ។

១៩ .នឹងជួញចេញគិតក្រោយ ទោះនឹងឲ្យៗមើលមុខ ។

២០ .នឹងលើរង្គើក្រោម ។

២១ .នឹងស៊ីចង់ពីសា ខ្ជិលទំពាឲ្យហ្មត់ហ្មង ។

២២ .នៅផ្ទះម្ដាយទីទៃ នៅព្រៃម្ដាយជាមួយ ។

២៣ .នំមិនដែលធំជាងនាឡិ ។

២៤ .នឿយណាស់កុំឲ្យដេកយកប្រពន្ធឲ្យមើលម្ដាយក្មេកចូលដំណេក កុំឲ្យនិយាយនឹងប្រពន្ធ ។

---

# ប

---

១ .បង់ពោយមិនមើលប្រាណ ដាំជើងក្រានមិនប្រមាណថ្ពាំង ។

២ .បញ្ញើទុកស្មើបំណុល ។

៣ .ប៉ស្តុកប៉ស្តា អ្នកមានប្រាជ្ញាក្រៃណា នឹងអ្នកមានភ័ព្វ ។

៤ .បន់ព្រះទៅសំពះឯប៉ាយ៉ាប បង់បញ្ចមហាប្រាសាទទៅនៅព្រៃស្មសាន បង់ពាក្យសមណព្រាហ្មណ៍ ទៅយកឯពាក្យពាល ។

៥ .បានតែបាបមិនធ្លាបមាត់ ។

៦ .បានពីក្អែកចែកទៅតាវើ ។

៧ .បានមកជាតូចរួចទៅជាធំ ។

៨ .បានមាសហើយ ក្រអីក្រដាសវេច ។

៩ .បានស្វាយ ណាយក្រូច ។

១០ .បាយកកក៏បាយ មេម៉ាយក៏ស្រី ។

១១ .បាយសិង្ហ៍ដទៅប្រមាទឯ កន្ទោងចំ ។

១២ .បុណ្យបាត់ដ្បិតបាប លាភបាត់ដ្បិតឃោរ ។

១៣ .បុណ្យក៏ធ្វើ ឈើក៏កាប់ សត្វក៏សម្លាប់ ច្បាប់ក៏កាន់ ។

១៤ .ប៉ុនក្រចកធ្វកជាធំ ។

១៥ .បួញមាត់បត់ជុំដៃ ។

១៦ .បួសដោយវត្ត ចិត្តដោយខ្លួន ។

១៧ .បួសមិនរៀនបន្ទោសថាខ្មៅ ។

១៨ .បើជំពប់ជើងគ្រាន់បិទ តែជំពប់មាត់បង់ប្រាក់ ។

១៩ .បើដុះបាច់អីផ្សាំ បើខ្លានឹងខាំបាច់អីនឹងចូលព្រៃ ។

២០ .បើចង់ពិសាឲ្យរកអន្ទក់ បើចង់ស្រណុកឲ្យនឿយ ។

២១ .បាយត្រជាក់ឲ្យតែសម្លក្តៅ ស្រីខ្មៅៗ ចុះឲ្យតែនៅក្មេង ។

២២ .បើកាចៗ ឲ្យគេកោត បើឆោតៗ ឲ្យគេអាណិត ។

២៣ .បើចង់ចំណេញកុំខ្លាចខាត បើចង់ស្អាតកុំខ្លាចយូរ ។

២៤ .បើមិនជួយចូក ជួយចែវ កុំយកជើងរាទឹក ។

២៥ .បើឮសូរផ្គរ កុំអាលចាក់ទឹកបំពង់ចោល ។

២៦ .បើលួចគេវាគ្រាន់ ប្រយ័ត្នតែគេទាន់វាក្រែល ។

២៧ .បើស៊ីត្រង់ណា កុំជុះត្រង់នោះ ។

២៨ .បើស៊ីកុំតាមឃ្លាន គិតប្រមាណអស់គ្នីគ្នា ។

២៩ .បើនឹងរស់ៗ ឲ្យគាប់ បើនឹងងាប់ៗ ឲ្យគួរ ។

៣០ .បើអាក្រក់ៗចុះឲ្យតែល្អ បើក្រៗចុះឲ្យតែមាន ។

៣១ .បែកមិត្រ កុំឲ្យយកជាមិត្រ ។

៣២ .បំណាច់នឹងចេះៗ តោងឲ្យគេកោត បំណាច់នឹងឆោតៗ ឲ្យគេអាណិត ។

៣៣.បំណាច់នឹងបាប តោងឲ្យធ្លាបមាត់ ។

៣៤ .បំណាច់នឹងខូចៗ ឲ្យបានការ បំណាច់គេថាតោងឲ្យសើមមាត់ ។

៣៥ .ប្រពន្ធពីរ គោបី ដំរីមួយ នាំឲ្យព្រួយចិត្ត ។

៣៦ .ប្រពន្ធល្អច្រើនចាញ់ប្ដី ពាក្យច្រើនកួតចាញ់អាត្មា ។

៣៧ .ប្រមាត់ដីចង់ឡើងទ្រើង ។

៣៨ .ប្រហែសវាបាត់ ប្រយ័ត្នវាគង់ ។

៣៩ .ប្រាក់ក៏បង់ ថង់ក៏ដាច ឬប្រាក់តែបង់ ថង់តែដាច គូថតែកាច កូនតែកើត ។

៤០ .ប្រាជ្ញពុំស្មើពុត ប្រើលំអុតពុំស្មើក្ដីគាប់ មានគុណពុំស្មើមានភ័ព្វ ។

៤១ .ប្រាជ្ញមិនស្មើប្រិប បំរើស្ទឹកត្រចៀកខ្ទប មិនស្មើអាឡេមឡឺម ។

៤២ .ប្រាជ្ញចុះរណ្ដៅ ខ្លៅឡើងសួគ៌ ។

៤៣ .ប្រាជ្ញអាងប្រាជ្ញា រមាសអាងបន្ទា ខ្លាអាងព្រៃ ដំរីអាងរនាម ត្រីអាងទឹក ទាហានអាងសឹក ប្រមឹកអាងពែង ។

៤៤ .ប្រាសពីដងរែក ទៅផ្ទែកលើពូកស៊ីសម្ងសាច់ជ្រូក បាយសុទ្ធអង្ករដើម ។

៤៥ .ប្រើត្រាប់សព្ទក្អែក កុំបីត្រាប់ពុតទន្សាយ ។

៤៦ .ប្រើត្រាប់កុកសាប់ កុំបីត្រាប់កុកស ។

៤៧ .ប្រើត្រាប់ឬស្សី កុំបីត្រាប់ស្នាយកន្ទ្រាញ ។

៤៨ .ប្រើត្រាប់អ្នកប្រាជ្ញប្រាយ កុំបីត្រាប់ខ្លៅសាមាន្យ ។

៤៨ .ប្រើទៅជាត្បូងចិញ្ចៀន ក្រវេចក្រវៀនជាមៀនកាំបិត ។

## ផ

១ .ផឹកស្រាក្នាសំដី ។

២ .ផ្ទុករទេះតាមចំណុះ ។

៣ .ផ្លូវវៀចកុំបាបង់ ផ្លូវណាត្រង់កុំដើរហោងដើរ ដោយស្នាមគន្លង
ដម្រាយអ្នកចាស់បុរាណ ។

៤ .ផ្លែត្រឡាចគង់មានបណ្ដូល មនុស្សទាំងមូលគង់មានចិត្ត ។

៥ .ផ្លែឈើចាញ់សន្ទឹក ត្រីច្រើនទឹកល្អក់ពុំជា ទ្រព្យច្រើនព្រួយរក្សា
ទ្រព្យតិចណា ព្រួយរិះគិត ។

## ព

១ .ពងមាន់កុំជល់នឹងថ្ម ឬពងមាន់សោត កុំប្រឡោតជល់នឹងថ្ម ។

២ .ពងមាន់ក្នុងសំបុកលោតទៅខាំក្អែក កង្កែបអាចម៍គោលោតទៅខាំ
ពស់វែក ត្រីក្នុងសង្រែកត្រវែងខាំឆ្មា ។

៣ .ពាក្យខុសកុំឲ្យស្ដាប់ សេចក្ដីគាប់ឲ្យរិះធ្យាន ។

៤ .ពាក្យក្រកុំអាលប្រាប់ ពាក្យឥតសព្ទកុំអាលថ្លែង ។

៥ .ពាក្យគ្រូវែងវីង ពាក្យពិតវែងស្វែង ។

៦ .ពាក្យពិតកុំឲ្យចែង ពាក្យពិតស្វែងពុំគួរលាក់ ។

៧ .ពាក្យព្រេងលោកស្រដី ជាកុំបីចិញ្ចឹមខ្លា ។

៨ .ពាក្យស្វែងកុំស្អប់ ពាក្យគាប់ឲ្យយក ។

៩ .ពាក្យម្ដាយ ទំនាយគ្រូ ។

១០ .ពិសាក្រៃណា នឹងឃ្លាន អាក្រកប៉ុន្មានក្រៃណានឹងស្រឡាញ់ ។

១១ .ពុតគ្រូកុំគ្រាប់ ច្បាប់គ្រូឲ្យយក ។

១២ .ពូជគោជ្រលែង ពូជស្រីប្ដីលែង ពូជសិស្សគ្រូបី ពូជខ្ញែបង់ម្ចាស់។

១៣ .ពួនតែមុខទុកគូថនៅកណ្ដាលវាល ។

១៤ .ពេទ្យគោលូន មេមត់ស្លាប់កូន សុភាចាញ់ក្ដី ឬពេទ្យគោលូន
មេមត់ស្លាប់កូន សុភាចាញ់ក្ដី ក្រពើលង់ទឹក ម្រឹគជាប់ព្រៃ ។

១៥ .ពោះជាទេវទត្ត មាត់ជាទេវតា ។

១៦ .ព្រះមិនសម ព្រហ្មមិនជួយ ។

១៧ .ពោះគោ ពោះក្របី ។

## ភ

១ .ភូតនៅហោរ ចោរនៅជាងទង ។

២ .ភ្លើងឆេះមកតែពីសម្រាម ។

៣. ភ្លេភ្លើ ដូចក្រពើវង្វេងបឹង ។

# ម

១ .មនុស្សកុំមើលងាយមនុស្ស ។

២ .មនុស្សខឹងកុំឲ្យលាងចាន មនុស្សឃ្លានកុំឲ្យដាំបាយ ។

៣ .មនុស្សខ្លាំងទុកជារបង មនុស្សកាចទុកខ្នង មនុស្សកោងទុកជាសម្រាស់ មនុស្សស្លូតទុកជារនាំង ។

៤ .មនុស្សឆ្លាតគេថាចោត មនុស្សល្ងូតគេថាល្ងង់ ចេះគេថាកាច ប្រាជ្ញគេថាព្រើល ។

៥ .មនុស្សទាបរៀងធ្វើខ្ពស់ ក្រទូរយស់រៀងអួតធន ខ្លាចរៀងធ្វើហ៊ាន គ្មានប្រាជ្ញារៀងអួតចេះ ។

៦ .មនុស្សនឹងប្រាក់ យក្សនឹងសាច់ ។

៧ .មាត់មានគ្រប ដបមានឆ្នុក ។

៨ .មាត់តែប្រកែក អម្រែកតែទទួល ។

៩ .មាត់ពីរោះ ពោះកាត់ក ។

១០ .មានគំនិតឥតកំណើត ។

១១ .មានធនប្រពន្ធមិនក្រ មានដីសមិនក្រក្តារខៀន មានរបៀន មិនក្ររបស់ ។

១២ .មាន់ណាខ្ដត មាន់នោះពង ។

១៣ .មានះបាត់មិត្រឥតអ្នកជាផៅ គ្រេវគ្រោធឃោរឃៅរមែងបាត់អង្គ។

១៤ .មានសម្រាមទើបឆ្កែវាជុះ ។

១៥ .មានទុក្ខមហាក្សត្រ មានទុក្ខចៅវត្ត មានទុក្ខស្រីមានរូប ។

១៦ .មានប្រឡាយទើបទឹកវាហូរ ។

១៧ .មាន់ពងលើជង្រុកស្រូវ ។

១៨ .មាន់ព្រៃកំចាយមាន់ស្រុក ។

១៩ .មិនជឿពាក្យស្រីអស់ស្រូវពូជ ។

២០ .មឹះៗ កេះផ្ទាំងបាយផ្ទុះ ។

២១ .មុខខ្មែ ស្រែជំពៅ ។

២២ .មេម៉ាយកូន១ ដូចព្រហ្មចារី មេម៉ាយកូន៣ ដូចស្រីសាវកែ ។

២៣ .ម្ទេះៗ ទៅយកឯជ័រញៀមកឡៀតក្ងៀក ។

២៤ .ម្ទេះៗ ទៅយកស្ករផ្ញើរនឹងស្រមោច ។

## យ

១ .យល់ញាតិឃ្លាតច្បាប់ ។

២ .យល់តូច កុំអាលខំ ទោះយល់ធំកុំអាលស្រាយ ។

## រ

១ .រទេះបាក់មិនគិត ទៅគិតឯគោលួចដាំង ។

២ .រទេះបាក់ត្រង់ណា ល្អិតស្នៅត្រង់ណោះ ។

៣ .រទីសរទាសដូចរាស្ត្រឥតស្តេច ។

៤ .របស់ព្រះ បូជាព្រះ ។

៥ .រនាបបាក់គ្រាន់នឹងជួស តែមាត់វាហួសកំពប់ប្រាក់ ។

៦ .រហ័សតែមាត់ ត្រគាកស្វាប់ស្អូក ។

៧ .រកឧសប្រទះឈើងាប់ ។

៨ .រស់នៅថាអាក្រក់ ស្លាប់បាត់មុខថាល្អ ។

៩ .រពឹសដៃផ្ទៃថ្អែត ។

១០ .ឫក្សជតា ក្រែណានឹងទន្សាកំណើត ។

១១ .ឫស្សី១ដើមនៅផ្សេងថ្នាំង បងប្អូនត្រឡាំងនៅផ្សេងចិត្ត ។

១២ .រេចទាំងលើទាំងក្រោមដូចត្បាល់កិន ។

១៣ .រោចគល់ រញ្ជួយដល់ចុង ។

## ល

១ .លាក់តែមុខដូចពង្រួល ។

២ .លិចសីមលោត ដល់កំប៉ូតសីមតោង ។

៣ .ល្ងង់ឲ្យមើលខ្យល់ ក្តីពុំយល់កុំអាលក្រោធ ។

៤ .លូកក្រហុកឲ្យកប់ដល់ក្លៀក ។

៥ .លួចគេវាផ្ទាប់ដៃ ដេកថ្ងៃវាផ្ទាប់ភ្នែក ។

៦ .លើកស្នាបង្ការភ្នែក ។

៧ .លេងនឹងក្មេងវាអប្បយស លេងនឹងពស់វាខាំដៃ លេងនឹងចាស់វាចង្រៃ ។

## វ

១. វៗ ឆ្កែទប្រហុកអស់ ។

២. វាយឲ្យយំហើយ ទើបបញ្ចុកចេកឲ្យ ។

## ស

១ .សត្វតុក្កែស្លាប់ដោយសារប្រើស ។

២ .សង់ផ្ទះតាមចិត្តអ្នកនៅ ។

៣ .សប្បុរសពេកចាញ់ធន នាទូជំនចាញ់ឥន្ទ្រីយ៍ ។

៤ .សាច់មិនបានស៊ី យកឆ្អឹងព្យួរក ។

៥ .សាបមួយដៃ ប្រៃមួយចឹប ។

៦ .ស៊ីច្រើនៗជុះ លេងច្រើនៗឈ្លោះ ដេកច្រើនៗខ្ជិល ។

៧ .ស៊ីនឹងអ្នកណា យកអាសាអ្នកនោះ ។

៨ .ស៊ីបាយដេក បាយសរសើរ ស៊ីបាយដើរបាយប្រទេចផ្កាសា ។

៩ .ស៊ីបាយនឹងពន្ទឹទៀន និយាយនឹងមនុស្សមានរបៀន សប្បាយស្តាប់ ស៊ីបាយនឹងពន្ទឺខ្យល់ និយាយនឹងមនុស្សកំហល់ ប៉ុនគេយកអង្រែបុកដើមទ្រូង ។

១០ .ស៊ីសាច់ដាច់មេត្តា សេពសុរាគ្មានពាក្យទៀង ។

១១ .សឹកដល់កុំអាលធ្លាយ ពាក្យពីឆ្ងាយកុំអាលយក ។

១២ .សួរកាប់កុំឲ្យជន្ទ សួរជេរមេដកទង់ជួរ កុំឲ្យថានៃរ៉ីយ ។

១៣ .សួរចូលកុំឲ្យចេញ សួរទិញកុំឲ្យដូរ ។

១៤ .ស្កូវទូលក្តិតបាវ កុំឲ្យទូលក្តិតកញ្ជើ ។

១៥ .ស្កូវបង់ប្រាក់មួយថង់ កុំឲ្យបង់ពាក្យសត្យ ។

១៦ .ស្កូវបែកក្បាលកុំឲ្យបែកផ្ទាំង ស្កូវបែកចង្កាដាំងកុំឲ្យស្រី
មើលងាយ ។

១៧ .ស្កូវឲ្យក្រពើលេប កុំឲ្យចង្វាប្របិច ។

១៨ .ស្កូវឲ្យសាច់កុំបង្ហាញព្រៃ ។

១៩ .ស្កូវយកសំផឹងធ្វើប្រពន្ធ កុំឲ្យតែប្រពន្ធធ្វើសំផឹង ។

២០ .ស្កូវស្លួចកុំឲ្យដាច់ គិតការពុំទាន់ស្រេចកុំអាលរន្ធត់ ។

២១ .ស្កូវស្លាប់បា កុំឲ្យស្លាប់មេ លង់ទូកកណ្ដាលទន្លេ កុំឲ្យតែភ្លើងឆេះ
ផ្ទះ ។

២២ .សំណាបយោងដី ស្រីយោងប្រុស ។

២៣ .ស្នាទ្រាំង ចម្ប៉ាំងស្ពោង ស្បោងបាភ្នំ ក្រមុំស្រុកចម្ការ ប្រាបឹង
ពេជតា ស្រាស្រុកពោធិ៍សាត់ ។

២៤ .សម្ងមិនឆ្ងាញ់ឲ្យតែក្ដៅ ប្រពន្ធខ្មៅឲ្យតែនៅក្មេង ។

២៥ .ស្លូឲ្យសាប អង្ក័យឲ្យទាប ប្រាជ្ញាឲ្យវៃ សំដីឲ្យខ្ពស់ ។

២៦ .សំឡេងប្រាប់ភាសា កិរិយាប្រាប់មារយាទ ។

២៧ .ស្លូសាច់កុក អាចម៍វាជាប្រហុក ពោមវាជាបន្លែ ។

២៨ .ស្ទឹកឈើជ្រុះមិនដែលឆ្ងាយពីគល់ ។

២៩ .ស្ទឹកឈើឥតកម្រើក បើកក្រើកដ្បិតខ្យល់បក់ ។

៣០ .ស្លូតស្លាប់ រៀចវរមានភ័ព្វ អាយុយឺនយូរ ។

៣១ .ស្ទៀកស្បង់មិនកោរសក់ ចុះកញ្ជក់ធ្មេចនេត្រា ។

៣២ .ស្វាមិនបង់បៀម សៀមមិនបង់ក្បួន យួនមិនបង់ពុត ខ្មែរស៊ុត ទ្រុតមិនបង់ចែចូវ ។

៣៣.ស្វែងរៀនរកច្បាប់ ពុំស្មើចិត្តជា ។

៣៤ .ស្នេហ៍មិនស្មើស្និទ្ធ ។

៣៥ .ស្អប់កុំឲ្យបាញ់ ស្រឡាញ់កុំឲ្យខ្ចី ។

៣៦ .ស្រឡាញ់ខ្លួនឲ្យស្ងួនចំណី ស្រលាញ់ប្ដីឲ្យស្ងួនចិត្ត ។

៣៧ .ស្រឡាញ់ពេញប្រាស ស្អប់ជំពប់លើ ។

៣៨ .ស្រម៉មិនដែលទុំ ក្រមុំមិនដែលស្ងួត ចង្កូតមិនដែលត្រង់ កំពង់មិនដែលស្ងាត់ មាត់មិនដែលស្ងៀម ។

៣៩ .ស្រឡាញ់ផ្លែឲ្យថែគល់ ។

៤០ .ស្រឡាញ់ម៉ែ ឲ្យថែកូន ។

៤១ .ស្រឡាញ់កុំឲ្យទៅញឹកៗ ដល់រលីកសឹមទៅម្ដងៗ ។

៤២ .ស្រីមួយដូចក្រូចមួយដើម ។

៤៣ .ស្រើបតាមផ្គរ អរតាមភ្លៀង ។

## ហ

១ .ហុតសម្លសំឡឹងកាក ហូតប្រវាក្រាកសំឡឹងជ្រោយ ។

២ .ហុចអំបោះមិនឲ្យស្រណោះដៃ ។

៣ .ហេតុមិនស្រឡាញ់សឹងថាឆ្ងាយ ទូកបែកសំពៅធ្លាយរសាត់ដល់
លង្កានាយ ស្រឡាញ់ហើយទើបទៅបាន ។

## អ

១ .អង្ករមួយក្ដាប់ បបរមួយថ្លាង ។

២ .អក្សរជាត្រី សំដីជាឯង លេខជាទោ ។

៣ .អណ្ដើកនៅជើង ចាំអីក្ដក់ហៅថ្កៃ ឬអណ្ដើកនៅជើង ចាំអីរកថ្កៃ ។

៤ .អណ្ដាតជាអាតកន្ទង បង់ទ្រព្យធនផងពីព្រោះអណ្ដាត ។

៥ .អត់មិនអត់យកកទៅលអន្ទាក់ ។

៦ .អន្ទង់ឲ្យឱនផុក រីឯកុកឱនត្រពាំង ។

៧ .អាក្រក់តែរូប ម្ហូបគេល្អ ល្អតែរូបម្ហូបមិនកើត ។

៨ .អាស្វាមិនទាន់ស្គាល់ព្រនង់ ។

៩ .អាវែកគេស៊ីក្រោមភ្នែក អាវែកមិនដឹងខ្លួន ។

១០ .ឥតដំបៅហៅជម្ងឺ ដំបៅមិនឈឺយកឈើចាក់ ។

១១ .ឥតទ្រព្យអប្បប្រាជ្ញា ។

១២ .អឹមជាងអៀម ស្ងៀមជាងស្រដី ។

១៣ .អួសទូកកុំឲ្យល្អាន ចាប់ត្រីបានកុំឲ្យល្អក់ទឹក ឬអួសទូកកុំឲ្យល្អាន

ទឹកថ្លាសោតកុំឲ្យល្អក់ ។

១៤ .អួសសម្រាស់ប្រទះពាក្យ ។

១៥ .អួតបេះរបេះក្បាច់ ។

១៦ .ឲ្យកូនគ្រាប់ពុតកង់ វិលគ្រប់អង្គត្រូវគ្រប់ប្រាណ ។

១៧ .អំបែងបែករកអំបែងណាដូច ។

# ចប់

# សុភាសិត

ស្លឲ្យសាប　　អង្គុយឲ្យទាប
ប្រាជ្ញាឲ្យទំទ៉　　សំដីឲ្យខ្ពស់ ៗ

ញ៉ុក ថែម